**Office of General Accounting**
440 North Broad Street
Portal B – Room 321
Philadelphia, PA 19130

ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០២៣

ជូនចំពោះ មាតាបិតា និងសិស្សានុសិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

យើងខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការជម្រាបលោកអ្នកថា ឥឡូវនេះ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ផ្តល់ប្រព័ន្ធ SchoolCash Online ដែលជាវិធីបង់ប្រាក់របស់យើងសម្រាប់ការទិញអ្វីៗទាំងអស់ពីសាលា រួមទាំងអ្វីៗគ្រប់យ៉ាង ចាប់ពីដំណើរកម្សាន្ត ទៅសៀវភៅប្រចាំឆ្នាំ។ គេហទំព័រ SchoolCash Online របស់យើងអាចឃើញនៅទីនេះ៖ https://philasd.schoolcashonline.com/ ។

## អ្វីៗដែលប្រព័ន្ធនេះផ្តល់ឱ្យ៖

- មានសុវត្ថិភាពជាងមុន - ឈប់ដាក់ប្រាក់ក្នុងខ្លួន ឬបាត់សែកទៀតហើយ!
- មានសុវត្ថិភាព - ប្រព័ន្ធ KEV មានសុវត្ថិភាព ហើយត្រូវបានការពារ
- ងាយស្រួលប្រើ។ ដូចគ្នានឹងគេហទំព័រពាណិជ្ជកម្មអេឡិចត្រូនិកផ្សេងទៀតដែរ ប្រព័ន្ធនេះទទួលយកកាតឥណទានធំៗភាគច្រើន
- ការរំលឹកតាមរយៈប្រព័ន្ធអេឡិចត្រូនិកនឹងជួយធានាថា មិនឱ្យហួសថ្ងៃកំណត់ដែលត្រូវបង់
- លោកអ្នកអាចឃើញការចំណាយក្នុងពេលកន្លងទៅ ដូច្នេះលោកអ្នកអាចដឹងនូវអ្វីៗដែលលោកអ្នកបានចំណាយទៅលើ

## របៀបដែលប្រព័ន្ធនេះដំណើរការ

ដំណើរការដោយក្រុម KEV Group, SchoolCash Online គឺជាក្រុមនាំមុខក្នុងឧស្សាហកម្មនេះ ក្នុងការគ្រប់គ្រងការបង់ប្រាក់សាលាដែលមានសុវត្ថិភាព និងមានសន្តិសុខ។ ប្រព័ន្ធនេះដាក់របស់របរទាំងអស់ដែលទាក់ទងនឹងសាលានៅក្នុងអ៊ិនធ័រណិត សម្រាប់សិស្សរបស់លោកអ្នកទិញ។ សាលា បង្ហោះ (post) របស់របរ និងសកម្មភាពរបស់ពួកគេ ហើយកំណត់ថ្លៃដែលពាក់ព័ន្ធទៅសិស្សរបស់លោកអ្នក ដើម្បីលោកអ្នកអាចទិញតាមអ៊ិនធ័រណិត ដោយប្រើកាតរបស់លោកអ្នក ដែលមានសញ្ញា Visa ឬ Mastercard ។ គ្រាន់តែចុចហើយបង់ប្រាក់! អ៊ីមែលដែលងាយស្រួលនឹងរំលឹកលោកអ្នកអំពីថ្ងៃកំណត់នាពេលខាងមុខ ហើយគណនីអនឡាញរបស់លោកអ្នកនឹងបង្ហាញការបង់ប្រាក់ពីមុនរបស់លោកអ្នកទាំងអស់ សម្រាប់ជាឯកសារយោងដ៏ងាយស្រួល។

## អត្ថប្រយោជន៍ដល់មាតាបិតា និងសាលា

SchoolCash Online ជួយឪពុកម្តាយ និងសមាជិកសហគមន៍បង់ប្រាក់សម្រាប់ការទិញរបស់របរផ្សេងៗដែលទាក់ទងនឹងសាលា ដោយសុវត្ថិភាព រហ័ស និង ងាយស្រួល។ បន្ថែមពីលើភាពងាយស្រួលសម្រាប់លោកអ្នក

លោកអ្នកនឹងជួយបង្កើនប្រសិទ្ធភាព និងសុវត្ថិភាព នៅសាលារបស់លោកអ្នក ដោយបង់ប្រាក់ដោយផ្ទាល់ទៅក្នុងគណនីធនាគាររបស់សាលាលោកអ្នក។ នេះអនុញ្ញាតឱ្យគ្រូបង្រៀន និងលេខាធិការផ្តោតលើការជួយសិស្ស មិនមែនរាប់លុយទេ។ លើសពីនេះទៀត លោកអ្នកទទួលដំណឹងភ្លាមៗអំពីសកម្មភាពរបស់សាលា និងថ្ងៃផុតកំណត់!

**ចុះឈ្មោះឥឡូវនេះ!**
ការចុះឈ្មោះសម្រាប់គណនី SchoolCash Online របស់លោកអ្នកដែលឥតចេញថ្លៃ ចំណាយពេលតិចជាងពីរនាទី ប៉ុណ្ណោះ! សូមមើលគេហទំព័រ https://philasd.schoolcashonline.com/ ហើយចុចលើពាក្យ Register។ លោកអ្នកក៏អាចចូលប្រើ SchoolCash Online តាមរយៈ គណនី Parent Portal របស់លោកអ្នកផងដែរ។ គ្មានគណនី Parent Portal ឬ? ចុច ទីនេះ ដើម្បីស្វែងយល់បន្ថែម និងចុះឈ្មោះ។

ប្រសិនបើលោកអ្នកជួបប្រទះការលំបាកអ្វីមួយ សូមទាក់ទងផ្នែកជំនួយការមាតាបិតារបស់ School Cash Online ដោយចូលមើល មជ្ឈមណ្ឌលផ្តល់ជំនួយសម្រាប់ SchoolCash Online ។

សូមអរគុណចំពោះការគាំទ្ររបស់លោកអ្នក!

ដោយសេចក្តីស្មោះស្ម័គ្រ

ការិយាល័យគណនេយ្យទូទៅ